# សេចក្តីប្រកាស

## ស្តីពីការជ្រើសរើសមន្ត្រីអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម ( TDSP )
## ក្រោមគម្រោងចំណាយប្រតិបត្តិការអាទិភាព ( POC )

យោងតាម ៖
- ប្រកាសលេខ ៥៥៧ សជណ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ ស្តីពីការឯកភាពជាគោលការណ៍លើការស្នើសុំអនុវត្តចំណាយប្រតិបត្តិការអាទិភាពសម្រាប់កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម(TDSP)របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ប្រកាសលេខ ១១២ MOC/SM 2011 ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ ស្តីពីការបង្កើត គណៈកម្មការជ្រើសរើសមន្ត្រីអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) ក្រោមគម្រោងចំណាយប្រតិបត្តិការអាទិភាព (POC)

ក្រសួងពាណិជ្ជកម្ម ត្រូវការ**ជ្រើសរើសមន្ត្រីចំនួន ២៥ រូប** ឲ្យចូលបម្រើការងារ ក្នុងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) តាមមុខតំណែង មានដូចខាងក្រោមនេះ ៖

១. នាយករងកម្មវិធីនៃគម្រោងចំណាយប្រតិបត្តិការអាទិភាព (POC) (ចំនួន ១ មុខតំណែង)
២. នាយកគម្រោងនៃកម្មវិធី TDSP (ចំនួន ១ មុខតំណែង)
៣. នាយករងគម្រោងនៃកម្មវិធី TDSP (ចំនួន ១ មុខតំណែង)
៤. អនុប្រធានផ្នែកហិរញ្ញវត្ថុ (ចំនួន ១ មុខតំណែង)
៥. មន្ត្រីបច្ចេកទេសហិរញ្ញវត្ថុ (គណនេយ្យករជាន់ខ្ពស់) (ចំនួន ១ មុខតំណែង)
៦. មន្ត្រីបច្ចេកទេសគណនេយ្យ (ចំនួន ១ មុខតំណែង)
៧. មន្ត្រីបច្ចេកទេសបេឡា (ចំនួន ១ មុខតំណែង)
៨. អនុប្រធានផ្នែកលទ្ធកម្ម (ចំនួន ១ មុខតំណែង)
៩. មន្ត្រីបច្ចេកទេសលទ្ធកម្ម (ចំនួន ២ មុខតំណែង)
១០. ប្រធានផ្នែកទ្រទ្រង់ស្ថាប័ន (ចំនួន ១ មុខតំណែង)
១១. អនុប្រធានផ្នែកទ្រទ្រង់ស្ថាប័ន (ចំនួន ១ មុខតំណែង)
១២. មន្ត្រីបច្ចេកទេសទ្រទ្រង់ស្ថាប័ន (ចំនួន ១ មុខតំណែង)
១៣. ប្រធានផ្នែកផែនការ និងទ្រទ្រង់ការអនុវត្តគម្រោង (ចំនួន ១ មុខតំណែង)
១៤. អនុប្រធានផ្នែកត្រួតពិនិត្យ និងវាយតម្លៃ (ចំនួន ១ មុខតំណែង)
១៥. មន្ត្រីបច្ចេកទេសត្រួតពិនិត្យ និងវាយតម្លៃ (ចំនួន ២ មុខតំណែង)
១៦. អនុប្រធានផ្នែកទ្រទ្រង់គម្រោង (ចំនួន ១ មុខតំណែង)
១៧. មន្ត្រីបច្ចេកទេសទ្រទ្រង់គម្រោង (ទ្រទ្រង់ការងារ IA) (ចំនួន ២ មុខតំណែង)
១៨. មន្ត្រីបច្ចេកទេសទំនាក់ទំនង (ចំនួន ២ មុខតំណែង)
១៩. ប្រធានផ្នែករដ្ឋបាល ផែនការ និងទ្រទ្រង់សសរស្តម្ភ (ចំនួន ១ មុខតំណែង)
២០. មន្ត្រីបច្ចេកទេសរដ្ឋបាល (ចំនួន ១ មុខតំណែង)
២១. មន្ត្រីបច្ចេកទេសទ្រទ្រង់សសរស្តម្ភ (ចំនួន ១ មុខតំណែង)

មន្ត្រីក្នុងក្របខ័ណ្ឌក្រសួងទាំងអស់ ដែលមានបំណងចង់ចូលរួមអនុវត្តគម្រោងនេះ សូមទំនាក់ទំនងនាយកដ្ឋានបុគ្គលិកដើម្បីទទួលបានព័ត៌មានលំអិត និងបំពេញបែបបទចាប់ពីពេលប្រកាសផ្សាយតទៅ (កាលបរិច្ឆេទផុតកំណត់ថ្ងៃ ០៦ ខែ មិថុនា ឆ្នាំ ២០១១)។

(មន្ត្រីរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិត្រូវបានផ្តល់អាទិភាព)